# សិលាចារឹកប្រាសាទភ្នំម្រេច K.178

ប្រាសាទភ្នំម្រេច មានទីតាំងភូមិសាស្ត្រស្ថិតនៅចម្ងាយ ៨០០ម៉ែត្រ ខាងលិចភូមិភ្នំម្រេច ស្រុកគូលែន ខេត្តព្រះវិហារ។ ប្រាសាទនេះសង់នៅលើចង្កេះភ្នំម្រេច មានប្រាង្គចំនួន២ សង់ឡើងអំពីឥដ្ឋ បែរមុខទៅទិសខាងកើត។ នៅលើបន្ទះមេទ្វាររបស់ប្រាសាទនេះមានសិលាចារឹកមួយចុះលេខសម្គាល់ K.178 ចារឹកជាភាសាសំស្ក្រឹត និងភាសាខ្មែរមានចំនួន ១៦ បន្ទាត់។

ជាសង្ខេបរួមមក បន្ទាត់ទី១ និងទី២ ចារឹកជាភាសាសំស្ក្រឹតបែប "វសន្តតិលកាឆន្ទ" ដែលពណ៌នាអំពីព្រះសិវក្នុងឥរិយាបថ ព្រហស្តម្ខាងកាន់លលាដ៍ក្បាល ម្ខាងកាន់កំសៀវទឹក និងមានបញ្ជាក់ឆ្នាំជាមហាសករាជឆ្នាំ ៩១៦ ត្រូវនឹងគ.ស.៩៩៤ ដែលស្ថិតនៅក្នុងរាជ្យរបស់ព្រះបាទស្រីជយវម៌្មទេវ (ទី៥) មានសប្បុរសជនម្នាក់នាមថា សោម បានបរិច្ចាគនូវដីធ្លីច្រើនកន្លែងនៅតំបន់ "គម្រ្យាង" ឬហៅតាមសិលាចារឹកថា ប្រទេសគម្រ្យាង។ ចាប់ពីបន្ទាត់ទី៣ ដល់បន្ទាត់ទី១៦ ចារឹកជាភាសាខ្មែរ ដែលរៀបរាប់អំពីតង្វាយដីធ្លី មានអ្នកបម្រើ និងការចង្វាត់ដី និងព្រំប្រទល់ដី។

តាមរយៈសិលាចារឹកនេះ យើងអាចស្រង់បានស្ថាននាមមួយចំនួន ដែលបង្ហាញអំពីទីតាំងភូមិសាស្ត្រ និងសណ្ឋានដីរបស់ប្រទេសកម្ពុជាសម័យបុរាណ និងបច្ចុប្បន្នបាន។ ស្ថាននាមទាំងនោះមានដូចជា៖

| | | |
|---|---|---|
| ១. គម្រ្យាង ប្រទេស | ២.ស្រេ គំម្រ្យាង៑ | ៣.ថ្នុលិ ត្រវាង៑ |
| ៤.ធ្បារិ វន្សិ | ៥.សំទិបិ | ៦.ផ្នុ រុង៑ |
| ៧. ស្រុកិ ជ្រែយិ វានិ | ៨.ស្រេ ទល្មាកិ ប៉េលិ | ៩.លាច បតៅ |
| ១០.ទំនប ស្ដេងបរមនាថ | ១១.លិង្វោង៑ កំត្យង៑ | ១២.វ្រះផ្លូ |
| ១៣.ឆ្នឹង៑ កន្រ្ទុមិ | ១៤.ត្រវាង៑ ថ្មសិ | ១៥.ស្តុកិ ប្រី |
| ១៦.សំទិបិ | ១៧. ត្រវាង៑ ជើងស្រុក | ១៨.ស្រេ ប្រលូង៑ |
| ១៩.ភូម្យ វេង្វោង៑ | ២០.ផ្លូ រុង៑ | ២១.តោកិ អំវិលិ |

**អត្ថបទពាក្យចារឹក**

១. ប្រាទាតិ ស្វបុម្បកវិណិ ស្វកមន្ទលុមយោ

ភក្ត្យា កបាលណិ និរន្តរធម៌មាត្កេ៍

២. សោមោ ហិ ណាម វិបុចន្ទ្រវិលេ ចកេ ច

អត្ថបទដោយ៖ កំ វណ្ណារ៉ា

គំម្រ្យាងប្រទេគពហុភូម្យតបោរនំ សះ។

៣. ចង្វត្តស្រែគំម្រ្យាង៑ គោល៑ កន្តាល៑ ថ្នល៑ ត្រវាង៑ ត៑ នៃឫតិយ គោល៑ ត៑ អគ្នេយ ប្រសប៑ ស្រែ

៤. ចំនាំ ធ្បារ៑ រន្សិ ទៅ សំទិប៑ ផ្ទុ រុង៑ ថ្វាយ៑ លុច៑ ស្រុក៑ ជ្រៃយ៑ វាន៑ ទៅ ល្វះ ត គោល៑ ព្ញគាន៑

៥. ប្រសប៑ ស្រែ ទល្នាក៑ បេ៑ល៑ អំរិ ត នោះហ៑ ទៅ ល្វះ ត គោល៑ ថ្មោតិវាយវ្យតោយ៑ ជេង៑ ត្បក៑

៦. តេល៑ ចំនត៑ វិចក្ស ចំវត្ត ភូម្យ លាច៑ បតៅ ត៑ ដោរ៑ វ្យរ៑ ឡ្នំ ក្រប៑ តោយ៑ បូវ៌ ទំនប៑

៧. ស្តេង៑ បរមនាថ ត៑ ទក្សិន ប្រសប៑ លិង្ងោង៑ កំត្យង៑ ត៑ បគ្និម ប្រសប៑ វ្រះ ផ្លូ ត៑ ឧ

៨. ត្តរ អង្វេ ធ្និង៑ កន្ទ្រម៑ ត៑ ឧត្តរ សោត៑ ចង្វត៑ ស្រែ ត្រវាង៑ ថ្មស៑ ត៑ ម្រតាញ៑ ភក្តិវិគ្រហ ដោ

៩. រ៑ នុ ប្រាក៑ ត វ្វំ ចញ៑ វេ្ង៑ ជ្យង៑ ៤ ត៑ បូវ៌ ប្រសប៑ ស្តុក៑ ប្រី ត៑ ទក្សិន សំទិប៑ ត្រវាង៑ ជេ

១០. ង៑ ស្រុក៑ នា ស្រែ ប្រលូង៑ ត៑ បគ្និម ប្រសប៑ ភូម្យ វេង្វោង៑ ត៑ ឧត្តរ ប្រសប៑ ផ្លូ រុង៑ ស្រែ

១១. កំលុង៑ វ្នំ ត៑ដោរ៑នុប្រាក៑សោលិង៑ ១០ខ្ញុំ២មាសិលិង៑១ ក្រប៑ ឡ្នំ ១ លង្គៅ ជ្យង៑ ២ ផ្នោល៑ ប

១២. រត៑ ២ ភូម្យ ប្រសាទ ត៑ បូវ៌ ប្រសប៑ ធោក៑ អំរិល៑ ត៑ ទក្សិណ ល្វះ ត ជេង៑ វ្នំ ត៑ បគ្និម

១៣. ល្វះ ត ត្រវាង៑ ត៑ ឧត្តរ ល្វះ ត ធ្និង៑ កន្ទ្រម៑ និយន ភូម្យ ត ពោះហ៑ នេះហ៑ អាយត្ត ត

១៤. តៃ ....តៃ កំបន៑ តៃ កំរ្យៅ តៃ កំបិត៑ តៃ.. នុ បំម្រេ ត កម្រតេង៑ ជគត៑ វ្វំ អាច៑ ត៑ ទារ៑

១៥. រាជការ្យ៑ នុ ចញ្ចូល៑ ផោង៑ វ្វំ អាច៑ ត៑ ជា គ្នាល៑ នៃ វ្រះ បំន្វស៑ ស្មិង៑ នុ ខ្ញោញ៑ បំម្រេ ត

១៦. កម្រតេង៑ ជគត៑ គុស៑ នេះ គ៑ ពោះហ៑ កល្បនា យាជមាន ត មាន៑ ភូម្យ នេះ នុ អ្នក៑ នេះ ។

## **បំណកប្រែ**

(១-២) ប្រាទាត៑ ស្វបុប្ផកវិណិ ស្វកមន្ទលុមយោ

ភក្ត្យា កបាលណិ និរន្តរធម៌មាគ៌្គេ

សោមោ ហិ ណាម វិបុចន្រ្ទវិលេ ចកេ ច

គំម្រ្យាងប្រទេគពហុភូម្យតបោរនំ សះ។

អ្នកមានព្រះហស្តកាន់លលាដ៍ក្បាល ដែលមានបុប្ផាក្នុងព្រហស្ត និងកំសៀវទឹក(កុន្ទី)ជាមាគ៌ា ដែលមាននិរន្តរភាពក្នុងធម៌។ គាត់ឈ្មោះសោម បានបរិច្ចាគទានក្នុងឆ្នាំសក. កំណត់ដោយ វិល=៩ ចន្រ្ទ=១វិបុ=៦ តបោវ៌នៃ និងដីជាច្រើនកន្លែងនៅតំបន់ គំម្រ្យាងប្រទេស។

(៣-៦) ចង្វាត់ (ព័ទ្ធដីបោះបង្គោល) ស្រែ គំម្រ្យាង គោល(បង្គោល) កណ្ដាល ថ្នល់ត្រពាំង ខាងទិស និរតិ គោល ខាងអគ្នេយ៍ ទៅប្រសព្វ ស្រែជាចំនាំ(វណ្ដាប់តង្វាយ)ច្បារ ឫស្សី ទៅដល់ សំទិប ផ្លូវរុង ខាងលិច ស្រុក ជ្រៃយ វាន ទៅដល់ គោល ព្ញសាន ប្រសព្វស្រែទល្នាក បេ៉ល រាប់គិត

ចាប់អំពីនោះទៅ រហូតទៅដល់គោល(បង្គោល) ថ្ម,ខាងភាគ ពាយព្យ ដោយដើងដេក ដែលជា ចំនត វិចក្សុ។

(៦-៨) ចង្វាត់ ភូមិ(ដី) លាច ផ្តៅ ដែលបានជាវ នឹងក្របី២នឹម ដោយគិតរាប់ចាប់ពីទិសបូព៌ ទំនប់ ស្តេង បរមនាថ,ខាងទក្សិណ (ខាងត្បូង) ប្រសព្វនឹង លិង្វោង កំត្យង, ខាងបស្ចឹម ប្រសព្វនិងព្រះផ្លូវ, ខាងឧត្តរ (ខាងជើង) ក្បែរស្ទឹង កន្ទ្រុម ខាងជើងទៀត។

(៨-១០) ចង្វាត់ ស្រែ ត្រពាំង ថ្មស ដែល ម្រតាញ ភក្តិវិគ្រហ បានជាវ នូវប្រាក់ដែលពុំចាញ់ភ្ញើងចំនួន៤ ជ្យង ខាងកើតប្រសព្វ នឹងស្តុកប្រី ខាងត្បូងសំទិប ត្រពាំងដើងស្រុក ស្រែប្រលូង ខាងលិចប្រសព្វនឹងភូមិ(ដី)វេង្វោង ខាងជើងប្រសព្វនឹងផ្លូវរុង(ផ្លូវធំ)។

(១១) ស្រែ កំឡុង ភ្នំ បានជាវនឹង ប្រាក់ ស ចំនួន១០ លិង អ្នកបម្រើ២នាក់ មាស១លិង ក្របី១នឹម លង្គៅ(ស្ពាន់)២ជ្យង គោឈ្មោល បរត(ក្អូរ ឬប្រណាំង) ២។

(១២-១៣) ភូមិ (ដី) ប្រសាទ(ថ្វាយ) ខាងកើតប្រសព្វ ឆោក អម្ពិល ខាងត្បូង ដល់ដើងភ្នំ ខាងលិច ដល់ត្រពាំង ខាងជើងដល់ស្ទឹងកន្ទ្រុម ។

(១៣-១៥) ដីធ្លី និងទ្រព្យសម្បត្តិទាំងនេះ ស្ថិតនៅក្រោម ការបង្គាប់ ..តែ ....តែ កំបនិ តែ កំប្រៅ តែ កំបិត តែ.. បម្រើចំពោះ កម្រតេង ជគត (ព្រះអាទិទេព) ពុំអាចទារ (ទទួល)រាជការ និង ចញ្ចូលិ(ប្រេង) ផង ពុំអាចជាគ្នាល (បម្រើ)ព្រះបំនូសស្មិង (បព្វជិតអ្នកធ្វើពិធីបូជា) និង ខ្លោញបម្រើ (ប្រធានអ្នកបម្រើ) ចំពោះកម្រតេង ជគត ជាដាច់ខាត។

(១៦) ទាំងនេះជាគ្រឿងតង្វាយសក្ការបូជា មានដីធ្លី និងអ្នកបម្រើ។

ជារួមមក សិលាចារឹកប្រាសាទភ្នំម្រេច គឺជាទិន្នន័យផ្នែកអក្សរសាស្ត្រដ៏សំខាន់មួយដែលបានប្រាប់អ្នកសិក្សាអំពីព្រឹត្តិការណ៍ដែលបានកើតឡើងនៅស.វ.ទី១០ ក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៥។ ជាពិសេស គឺព័ត៌មានដែលរៀបរាប់អំពីការបរិច្ចាកដីបម្រើដល់ផ្នែកសាសនា និងស្ថាននាមជាច្រើនកន្លែងនៅក្នុងដែនកម្ពុជាបុរាណ៕

អត្ថបទដោយ៖ កំ វណ្ណារ៉ា



រូបលេខ១៖ ប្រាសាទភ្នំម្រេច មើលពីទិសឦសាន



រូបលេខ២៖ សកម្មភាពផ្តិតសិលាចារឹកប្រាសាទភ្នំម្រេច

អត្ថបទដោយ៖ កំ វណ្ណារ៉ា



រូបលេខ៦២៖ ប្រាសាទភ្នំម្រេចតួប៉មខាងជើង

អត្ថបទដោយ៖ កំ វណ្ណាក់



រូបលេខ៣៖ ប្រាសាទភ្នំម្រេចតួប៉មខាងត្បូង

អត្ថបទដោយ៖ កំ វណ្ណារ៉ា



រូបលេខ៥៖ ក្រដាសផ្ដាមសិលាចារឹកភ្នំម្រេច (ផ្ដិតដោយ៖ កំ វណ្ណាវ៉ា)

អត្ថបទដោយ៖ កំ វណ្ណាវ៉ា